**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខ : ៥១២ ប្រ.ក ប.ស្ត

# ប្រកាស
## ស្តីពី
## ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិចារ្យ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៩១៣/៩០៣/ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត/០៤១៦/៣៦៨/ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់ និងតែងតាំងមុខងារ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣៥អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញលិខិតចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី»
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១.**_

ត្រូវបានទទួលស្គាល់សហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិចារ្យ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

**ប្រការ២._**

សហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានផ្ទៃដីទំហំ ១១៩០ហិកតា (មួយពាន់មួយរយកៅសិបហិកតា) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ និងមាននិយាមកា (Datum: WGS 1984) ដូចខាងក្រោម៖

| ID | ចំណុច | X | Y | ID | ចំណុច | X | Y |
|---|---|---|---|---|---|---|---|
| 1 | A | ៤៥៥៦៨៣ | ១៥៦២៧៣៣ | 5 | E | ៤៥៤៦១៩ | ១៥៥៩៨៧៥ |
| 2 | B | ៤៥៨២០២ | ១៥៦២៨២៩ | 6 | F | ៤៥៤៨០៧ | ១៥៦១២៨១ |
| 3 | C | ៤៥៨១៩៦ | ១៥៥៨៨៥៦ | 7 | G | ៤៥៥២៤៨ | ១៥៦១៨២០ |
| 4 | D | ៤៥៦២៥៦ | ១៥៥៨៩៧៨ | 8 | H | ៤៥៥២៧៥ | ១៥៦២៣៧៥ |

**ប្រការ៣._**

ការរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិអាផ្លោញភ្នំដី ក្នុងគោលបំណងបង្កើនការចូលរួមគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងរួមចំណែកលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋានស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**ប្រការ៤._**

សហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន នៃក្រសួងបរិស្ថាន។ សហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» ត្រូវរៀបចំលក្ខន្តិកៈ និងផែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងសហគមន៍តំបន់ការពារធម្មជាតិ «អាផ្លោញភ្នំដី» ត្រូវអនុវត្តន៍ប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ខែ ធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

សាយ សំអាល់

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះវិហារ
- ដូចប្រការ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

... ស្ថិតក្នុងដែនជម្រកសត្វព្រៃ គូលែន-ព្រហ្មទេព

ភូមិសាស្ត្រភូមិចាប្ញ ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

ឧបសម្ព័ន្ធ: ប្រកាសលេខ ....
ចុះថ្ងៃទី ០៩..... ខែ ......... ឆ្នាំ២...
របស់ក្រសួងបរិស្ថាន




| Id | Name | X | Y |
|---|---|---|---|
| 1 | A | 455683 | 1562733 |
| 2 | B | 458202 | 1562729 |
| 3 | C | 458196 | 1558856 |
| 4 | D | 456254 | 1558978 |
| 5 | E | 454619 | 1559875 |
| 6 | F | 454807 | 1561281 |
| 7 | G | 455248 | 1561820 |
| 8 | H | 455275 | 1562375 |